# លក្ខន្តិកៈ
## មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត

*STATUTE*

*DEAD FUND OF CAPITAL AND PROVINCIAL COUNCILS*

# បុព្វកថា

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

ប្រការ ១ *ឈ្មោះ*

ប្រការ ២ *វិសាលភាព និងការចូលជាធរមាន*

## ជំពូក ២

## អាសយដ្ឋាន រូបសញ្ញា និងត្រា

ប្រការ ៣ *អាសយដ្ឋាន*

ប្រការ ៤ *រូបសញ្ញា និងត្រា*

## ជំពូក ៣

## គោលបំណង និងទិសដៅ

ប្រការ ៥ *គោលបំណង*

ប្រការ ៦ *ទិសដៅ*

## ជំពូក ៤

## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

ប្រការ ៧ *រចនាសម្ព័ន្ធ*

ប្រការ ៨ *ក្រុមប្រឹក្សាសមាគមជាតិ*

ប្រការ ៩ *គណៈកម្មាធិការប្រតិបត្តិ*

ប្រការ ១០ *អគ្គលេខាធិការដ្ឋាន*

ប្រការ ១១ *កម្រងរាជធានី ខេត្ត*

## ជំពូក ៥
## សមាជិកភាព

ប្រការ ១២ *សមាជិកភាព*

ប្រការ ១៣ *បែបបទនៃការសុំចូលជាសមាជិករបស់មូលនិធិ*

ប្រការ ១៤ *ពាក្យបណ្តឹង*

ប្រការ ១៥ *ការបាត់បង់សមាជិកភាព*

ប្រការ ១៦ *ការចូលជាសមាជិកភាពសាជាថ្មី*

## ជំពូក ៦
## ករណីកិច្ច និងផលប្រយោជន៍របស់សមាជិក

ប្រការ ១៧ *ករណីយកិច្ចរបស់សមាជិក*

ប្រការ ១៨ *ផលប្រយោជន៍របស់សមាជិក*

ប្រការ ១៩ *សិទ្ធិទទួលបានប្រាក់ឧបត្ថម*

ប្រការ ២០ *ករណីមិនបានធ្វើបណ្តាំ ឬមរណភាពទាំងអ្នកផ្តាំ និងអ្នកទទួលបណ្តាំ*

## ជំពូក ៧
## មូលនិធិ និងការគ្រប់គ្រងមូលនិធិមរណៈសង្គ្រោះ

ប្រការ ២១ *ប្រភពមូលនិធិ*

ប្រការ ២២ *ការគ្រប់គ្រង និងរក្សាសាច់ប្រាក់*

## ជំពូក ៨
## គោលការណ៍ប្រតិបត្តិការមូលនិធិមរណៈសង្គ្រោះ

ប្រការ ២៣ *ប្រតិបត្តិការសាច់ប្រាក់នៅធនាគារ*

ប្រការ ២៤ បេឡាសាច់ប្រាក់របស់មូលនិធិ

ប្រការ ២៥ ប្រតិបត្តិការរដ្ឋបាល

ប្រការ ២៦ របាយការណ៍មូលនិធិ


## ជំពូក ៩
## វិសោធនកម្ម និងការរំសាយមូលនិធិ


ប្រការ ២៧ វិសោធនកម្ម ឬកែសម្រួលលក្ខន្តិកៈ

ប្រការ ២៨ ការរំសាយ និងការចាត់ចែងទ្រព្យសម្បត្តិ


## ជំពូក ១០
## អវសានប្បញ្ញត្តិ


ប្រការ ២៩ សុពលភាពគតិយុត្ត

# បុព្វកថា

ដោយយោងតាមការស្នើសុំរបស់សមាជិកក្រុមប្រឹក្សាសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ស្តីពីការបង្កើត " **មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត** " ពីសំណាក់ក្រុមប្រឹក្សារាជធានី ខេត្ត ទូទាំង២៥ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានគំនិតផ្តួចផ្តើមដើម្បីបង្កើតឡើងនូវ "**មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត**"។

**មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត** គឺជាតំណាងឆន្ទៈរួមរបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងគោលបំណងពង្រឹងនូវចំណងមិត្តភាព សាមគ្គីភាព និងជួយឧបត្ថម្ភគ្នាទៅវិញ ទៅមក រវាងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នៅពេលមានទុក្ខធុរៈ ពិសេសដោយទទួលមរណភាព ឬសហព័ទ្ធទទួលមរណភាព ឬរងគ្រោះដោយអគ្គិភ័យឆេះលំនៅដ្ឋានចាប់ពី ៥០%(ហាសិបភាគរយ) ឡើងទៅ។

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._** ***ឈ្មោះ***

មូលនិធិនេះមានឈ្មោះថា " **មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត** " សរសេរជាអក្សរកាត់ថា: **ម.ម.ស.ក.រ.ខ** និងមានឈ្មោះជាភាសាអង់គ្លេសថា: *Dead Fund of Capital and Provincial Councils (DFCPC)*។

**ប្រការ ២._** ***វិសាលភាព និងការចូលជាធរមាន***

លក្ខន្តិកៈនេះមានវិសាលភាពអនុវត្តក្នុងក្របខ័ណ្ឌក្រុមប្រឹក្សារាជធានី ខេត្ត នៅក្នុងប្រទេសកម្ពុជា និងអតីតសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលបាននឹងកំពុងបន្តបង់ប្រាក់សមាជិកភាពជូនដល់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត។

លក្ខន្តិកៈនេះ ចូលជាធរមានបន្ទាប់ពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសមាគម នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

*សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសមាគមនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវអនុម័តដោយការបោះឆ្នោតដែលមានសំឡេងគាំទ្រយ៉ាងតិច លើសពីពាក់កណ្តាល (ហាសិបភាគរយបូកមួយ) លើកូរ៉ុមចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិច ពីរភាគបី នៃចំនួនសមាជិកក្រុមប្រឹក្សាសមាគម នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ។*

## ជំពូក ២
## អាសយដ្ឋាន រូបសញ្ញា និងត្រា

**ប្រការ ៣._ *អាសយដ្ឋាន***

*មូលនិធិមរណសង្គ្រោះសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានអាសយដ្ឋាននៅក្នុងអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

**ប្រការ ៤._ *រូបសញ្ញា និងត្រា***

*រូបសញ្ញា និងត្រា ជាផ្លូវការរបស់មូលនិធិមរណសង្គ្រោះសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត គឺប្រើប្រាស់រូបសញ្ញា និងត្រារបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

## ជំពូក ៣
## គោលបំណង និងទិសដៅ

**ប្រការ ៥._ *គោលបំណង***

*មូលនិធិមរណសង្គ្រោះសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានគោលបំណងដូចខាងក្រោម៖*

- *ជួយសម្រាលនូវទុក្ខលំបាក ទាំងខាងផ្លូវចិត្ត និងផ្លូវសម្ភារៈ ដល់ស្វាមី ឬភរិយា របស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នៅពេលទទួលមរណភាព*
- *ជួយសម្រាលនូវទុក្ខលំបាករបស់សមាជិក នូវពេលជួបឧបទ្ទវហេតុដោយ ថែជន្យអគ្គីភ័យឆេះលំនៅដ្ឋានចាប់ពី ៥០% (ហាសិបភាគរយ) ឡើងទៅ*

- បង្កើនចំណងមិត្តភាព សាមគ្គីភាព ជួយឧបត្ថម្ភគ្នាទៅវិញ ទៅមក រវាងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត

ប្រការ ៦._ ***ទិសដៅ***

ដើម្បីសម្រេចនូវគោលបំណងខាងលើ មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត មានទិសដៅដូចខាងក្រោមៈ

- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍន៍នានា សប្បុរសជនក្នុង និងក្រៅប្រទេស ដើម្បីសុំការជួយឧបត្ថម្ភ គាំទ្រ ទាំងផ្នែកធនធាន មធ្យោបាយ សំភារៈ និងថវិកា ដល់មូលនិធិមរណសង្គ្រោះក្នុងការបំពេញគោលបំណងរបស់ខ្លួនឲ្យបានសម្រេច
- ផ្តល់ជូនដោយផ្ទាល់នូវសំភារៈ និងថវិកា ដល់សហព័ទ្ធនៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នៅពេលសមាជិកណាម្នាក់ទទួលមរណភាព ឬទទួលរងនូវគ្រោះអគ្គីភ័យភ្លើងឆេះលំនៅដ្ឋានលើសពី៥០%ឡើងទៅ។

## ជំពូក ៤
## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

ប្រការ ៧._ ***រចនាសម្ព័ន្ធ***

មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត រមានរចនាសម្ព័ន្ធដូចខាងក្រោមៈ

- ក្រុមប្រឹក្សាសមាគមជាតិ
- គណៈកម្មាធិការប្រតិបត្តិជាតិ
- អគ្គលេខាធិការដ្ឋាន
- កម្រងរាជធានី ខេត្ត

ប្រការ ៨._ ***តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិ***

ក្រុមប្រឹក្សាជាតិមានតួនាទី និងភារកិច្ចៈ

- ពិនិត្យ និងអនុម័ត សេចក្តីសម្រេចលក្ខន្តិកៈមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត
- ពិនិត្យ និងធ្វើវិសោធនកម្ម លក្ខន្តិកៈមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត
- ពិនិត្យ និងវាយតម្លៃ របាយការណ៍ប្រចាំឆ្នាំរបស់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រតិភូកម្ម សិទ្ធអំណាចក្នុងការសម្រេចការងារចាំបាច់ដ៏ទៃទៀតដល់គណៈកម្មាធិការប្រតិបត្តិជាតិ។

ប្រការ ៩._ ***តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ***

គណៈកម្មាធិការប្រតិបត្តិជាតិមានតួនាទី និងភារកិច្ចៈ

- តាមដាន និងវាយតម្លៃលើការអនុវត្តការងារ បញ្ហាប្រឈម និងដំណោះស្រាយ ក្នុងការអនុវត្តមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត
- ផ្តួចផ្តើម និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិ
- ប្រតិភូកម្ម សិទ្ធអំណាចក្នុងការសម្រេចការងារចាំបាច់ដ៏ទៃទៀតដល់ប្រធាន អនុប្រធានសមាគមជាតិ។

ប្រការ ១០._***តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន***

អគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត គឺជាសេនាធិការឲ្យថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងការអនុវត្ត តួនាទី ភារកិច្ចបន្ថែមលើការងារស្នូលរបស់ខ្លួនចំពោះមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត។

អគ្គលេខាធិការមានភារកិច្ចៈ

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់មូលនិធិ
- គ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់មូលនិធិ

- ផ្តល់យោបល់ និងរៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាសមាគមជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ និងប្រធាន អនុប្រធានសមាគមជាតិ
- ទទួលខុសត្រូវកិច្ចការផ្សេងទៀត តាមល័ក្ខខ័ណ្ឌការងារចាំបាច់។

**ប្រការ ១១._តួនាទី និងភារកិច្ចរបស់កម្រងរាជធានី ខេត្ត**

កម្រងរាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោមៈ

- អនុវត្តនិងផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អំពីសេចក្តីសម្រេចលក្ខន្តិកៈមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត
- ចុះឈ្មោះ និងធ្វើបញ្ជីឈ្មោះសមាជិកបញ្ជូនទៅអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រមូលភាគទានពីសមាជិកបញ្ជូនទៅអគ្គលេខាធិការដ្ឋាន សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នៅសប្តាហ៍ទី២ រៀងរាល់ខែ
- ទទួលភាគទានពីសមាជិក ឬពីមជ្ឈដ្ឋាននានាបញ្ជូនទៅអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- លើកសំណើរភ្លាមមកថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីផ្តល់ប្រាក់សង្គ្រោះដល់សមាជិកមូលនិធិ ឬភរិយា-ស្វាមីស្របច្បាប់របស់សមាជិកនៅពេលសមាជិកឬសហព័ទ្ធទទួលមរណភាព ឬរងគ្រោះដោយអគ្គីភ័យឆេះលំនៅដ្ឋានចាប់ពីហាសិបភាគរយឡើងទៅ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ
- ចាត់តាំងសមាជិកសមាគមក្នុងមូលដ្ឋានរបស់ខ្លួន ដោយសហការជាមួយបុគ្គលិកនៅក្នុងអគ្គលេខាធិការដ្ឋានសមាគមជាតិ និងក្រុមគ្រួសារនៃសមាជិកមូលនិធិ ដើម្បីរៀបចំពិធីបុណ្យនៅពេលសមាជិកមូលនិធិក្នុងមូលដ្ឋានរបស់ខ្លួនទទួលមរណភាព និងចាត់ចែងកិច្ចការដ៏ទៃទៀតដែលជាប្រយោជន៍ស្របច្បាប់ដល់មូលនិធិ។

# ជំពូក ៥
# សមាជិកភាព

**ប្រការ ១២._*សមាជិកភាព***

សមាជិកមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត រួមមានៈ
-សមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា
-អតីតសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលបាន នឹងកំពុងបន្តបង់ប្រាក់សមាជិកភាពជូនដល់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត។

**ប្រការ ១៣._*បែបបទនៃការសុំចូលជាសមាជិករបស់មូលនិធិ***

បែបបទនៃការសុំចូលជាសមាជិកមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត រួមមានៈ

- ពាក្យសុំចូលជាសមាជិករបស់មូលនិធិដែលមានបិទរូបថត (៤x៦) ចំនួន ០១ច្បាប់
- រូបថតចំនួន ០៣សន្លឹក ដែល០១សន្លឹក ទំហំ (៤x៦) សម្រាប់បិទបញ្ជីអត្តលេខនិង ០១សន្លឹកទៀត ទំហំ (៣x៤) សម្រាប់បិទលើប័ណ្ណសមាជិក
- ពាក្យបណ្តាំបិទស្រោមជិត ០១ច្បាប់ ដូចមានគម្រូក្នុងលក្ខន្តិកៈនេះ ដែលសរសេរដោយផ្ទាល់ដៃសម្រាប់តម្កល់ទុកជាឯកសារសំងាត់ នៅក្នុងការិយាល័យអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

**ប្រការ ១៤._*ពាក្យបណ្តាំ***

ពាក្យបណ្តាំអាចកែប្រែនៅថ្ងៃណាមួយក៏បាន តាមការស្នើសុំរបស់សាមីខ្លួន ដោយត្រូវផ្ញើរពាក្យបណ្តាំថ្មី មកការិយាល័យអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ទើបចាត់ទុកថាបានការ។ ពាក្យបណ្តាំចុងក្រោយបង្អស់ទើបចាត់ទុកជាផ្លូវការ។

**ប្រការ ១៥._*ការបាត់បង់សមាជិកភាព***

សមាជិកមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត អាចបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

- បានសុំលាឈប់ពីមូលនិធិមរណសង្គ្រោះជាលាយល័ក្ខណ៍អក្សរ
- មិនបានបង់ភាគទាន ០៣(បី) លើក ជាប់ៗ ក្រោយពេលដែលថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានធ្វើការក្រើនរំលឹកជាលាយល័ក្ខណ៍អក្សរចំនួន ០៣(បី)លើក រួចហើយ
- ត្រូវបានបណ្តេញចេញពីមូលនិធិ ក្នុងករណីសមាជិកនោះមិនព្រមអនុវត្តតាមលក្ខន្តិកៈ ឬប្រព្រឹត្តផ្ទុយពីសកម្មភាពរបស់មូលនិធិ។

**ប្រការ ១៦._*ការចូលសមាជិកភាពសាជាថ្មី***

សមាជិកមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ដែលបានសុំលាឈប់ ឬត្រូវបានលុបឈ្មោះចេញពីមូលនិធិ ពុំមានសិទ្ធិទាមទារប្រាក់ដែលខ្លួនបានបង់ជូនមូលនិធិរយៈពេលកន្លងមកនោះទេ។

សមាជិកភាពមូលនិធិណាម្នាក់ដែលបាត់បង់សមាជិកភាពរបស់ខ្លួន ហើយមានបំណងចូលជាសមាជិកមូលនិធិវិញត្រូវធ្វើពាក្យសុំចូលជាថ្មីសាឡើងវិញហើយត្រូវបង់ភាគទានបំពេញមកវិញ ក្នុងចន្លោះពេលដែលខ្លួនខកខានពុំបានបង់ និងដោយមានការយល់ព្រមពីថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

## ជំពូក ៦
## ការណីយកិច្ច និងផលប្រយោជន៍របស់សមាជិក

**ប្រការ ១៧._*ករណីយកិច្ចរបស់សមាជិក***

សមាជិកមូលនិធិមរណសង្គ្រោះសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានករណីយកិច្ចដូចខាងក្រោម៖

- ត្រូវបង់ប្រាក់ចំនួន ២០.០០០៛០០ (ម្ភៃពាន់រៀលគត់) ជាបរិវិសទាន (សិទ្ធិសុំចូលជាសមាជិក) នៅពេលដាក់ពាក្យសុំចូលជាសមាជិករបស់មូលនិធិ

- *ត្រូវបង់ប្រាក់ចំនួន ១៥.០០០៛០០ (ដប់ប្រាំពាន់រៀលគត់) ក្នុង ១ករណី។ ក្នុងករណីសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ណាម្នាក់ ទទួលមរណភាព*
- *ត្រូវបង់ប្រាក់ចំនួន ១០.០០០៛០០ (ដប់ពាន់រៀលគត់) ក្នុង ១ករណី។ ក្នុងករណីសហព័ទ្ធ (ប្តី ឬប្រពន្ធស្របច្បាប់) សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ណាម្នាក់ ទទួលមរណភាព ។*
- *ត្រូវបង់ប្រាក់ចំនួន ១៥.០០០៛០០ (ដប់ប្រាំពាន់រៀលគត់) ក្នុង១ករណី។ ក្នុងករណីសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ណាម្នាក់ ទទួលរងនូវគ្រោះថ្នាក់ផ្ទះលំនៅដ្ឋានអស់ចាប់ពីហាសិបភាគរយឡើងទៅ។*

ប្រការ ១៨._***ផលប្រយោជន៍របស់សមាជិក***

*សមាជិកមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត អាចទទួលផលប្រយោជន៍ពីមូលនិធិមរណសង្គ្រោះស្មើរៗគ្នា ដូចខាងក្រោមៈ*

**១-ករណីមរណភាព**

- *ទទួលប្រាក់ឧបត្ថមចំនួន ៤.០០០.០០០៛០០ (បួនលានរៀលគត់) ចំពោះសមាជិកមូលនិធិមរណសង្គ្រោះជាក្រុមប្រឹក្សារាជធានី ខេត្ត ណាម្នាក់ ដែលបានទទួលមរណភាព*
- *ទទួលប្រាក់ឧបត្ថមចំនួន ៤.០០០.០០០៛០០ (បួនលានរៀលគត់) ចំពោះសមាជិកមូលនិធិមរណសង្គ្រោះជាអតីតសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ណាម្នាក់ ដែលបានទទួលមរណភាព (ក្នុងករណីនៅតែបន្តបង់មូលនិធិ)*
- *ទទួលប្រាក់ឧបត្ថមចំនួន ៣.០០០.០០០៛០០ (បីលានរៀលគត់) ចំពោះសហព័ទ្ធ(ភរិយា ឬស្វាមីស្របច្បាប់ ) របស់ក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាសមាជិកមូលនិធិមរណសង្គ្រោះណាម្នាក់ ដែលបានទទួលមរណភាព*
- *ទទួលប្រាក់ឧបត្ថមចំនួន ៣.០០០.០០០៛០០ (បីលានរៀលគត់) ចំពោះសហព័ទ្ធ (ភរិយា ឬស្វាមីស្របច្បាប់ ) របស់អតីតសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាសមាជិកមូលនិធិមរណសង្គ្រោះណាម្នាក់ដែលបាន*

ទទួលមរណភាព។ (ក្នុងករណីនៅតែបន្តបង់មូលនិធិ)

**២-ករណីអគ្គីភ័យឆេះលំនៅដ្ឋានចាប់ពីហាសិបភាគរយ**

- ទទួលប្រាក់ឧបត្ថមចំនួន ៤.០០០.០០០៛០០ (បួនលានរៀលគត់) ចំពោះសមាជិកមូលនិធិមរណសង្គ្រោះជាក្រុមប្រឹក្សារាជធានី ខេត្ត ជាអតីតក្រុមប្រឹក្សារាជធានី ខេត្ត (ក្នុងករណីនៅតែបន្តបង់មូលនិធិ) ណាម្នាក់ ដែលរងការឆេះលំនៅដ្ឋានចាប់ពីហាសិបភាគរយឡើងទៅ។

ប្រការ ១៩._***សិទ្ធទទួលបានប្រាក់ឧបត្ថម***

អ្នកដែលមានសិទ្ធិទទួលបានប្រាក់ឧបត្ថមដូចមានចែងក្នុង ប្រការ១៤ នៃលក្ខន្តិកៈនេះ គឺជនទាំងឡាយណា ដែលមានឈ្មោះនៅក្នុងពាក្យបណ្តាំចុងក្រោយ។

អ្នកទទួលសិទ្ធិក្នុងពាក្យបណ្តាំ ត្រូវមានអត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានលើករណី ខ្លួនជាស្វាមី ឬភរិយា ឬញាតិពន្ធ ឬជាអ្នកទទួលសិទ្ធិតាមពាក្យបណ្តាំរបស់អ្នកស្លាប់ លិខិតបញ្ជាក់មរណភាព ឬលិខិតបញ្ជាក់របស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

ប្រការ ២០._***ករណីមិនបានធ្វើបណ្តាំ ឬមរណភាពទាំងអ្នកផ្តាំ និងអ្នកទទួលបណ្តាំ***

ចំពោះសមាជិកមូលនិធិណាមួយ ដែលមិនបានធ្វើពាក្យបណ្តាំ ឬទាយាទដែលនឹងត្រូវទទួលពាក្យបណ្តាំ បានទទួលមរណភាពក្នុងពេលតែមួយជាមួយសមាជិកមូលនិធិ នោះប្រាក់ឧបត្ថមដូចមានចែងក្នុង ប្រការ១៨ នៃលក្ខន្តិកៈនេះ នឹងត្រូវផ្តល់ជូនតាមការសម្រេចរបស់ថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដល់ទាយាទ ឬញាតិពន្ធ សម្រាប់ចាត់ចែងធ្វើបុណ្យសពតាមប្រពៃណី។

## ជំពូក៧
## មូលនិធិ និងការគ្រប់គ្រងមូលនិធិ

ប្រការ ២១._***ប្រភពមូលនិធិមរណសង្គ្រោះ***

មូលនិធិមរណៈសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត បានប្រភពមកពី៖

- ❖ ប្រាក់បរិវិសទាន របស់សមាជិក
- ❖ ប្រាក់ភាគទាន (ក្នុង១ករណី) របស់សមាជិក
- ❖ អំណោយជាសំភារៈ ឬថវិកាពីសប្បុរសជននានា និងអង្គការជាតិ និង អន្តរជាតិ
- ❖ ប្រភពចំណូលផ្សេងៗទៀតដែលបានមកពីសកម្មភាពស្របច្បាប់របស់សមាគម។

ប្រការ ២២._***ការគ្រប់គ្រង និងរក្សាសាច់ប្រាក់***

រាល់ចំណូលថវិកាទាំងអស់របស់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវគ្រប់គ្រងដោយអគ្គលេខាធិការសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

ថវិកាមូលនិធិមរណសង្គ្រោះ ត្រូវផ្ញើរទុកនៅក្នុងគណនីធនាគារក្នុងនាមសមាគម នៅធនាគារណាមួយនៅក្នុងប្រទេសកម្ពុជា ដែលមានការទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងមានសាខារបស់ខ្លួននៅតាមរាជធានី ខេត្ត។

## ជំពូក៨
## គោលការណ៍ប្រតិបត្តិការនៃមូលនិធិមរណសង្គ្រោះ

ប្រការ ២៣._***ប្រតិបត្តិការសាច់ប្រាក់នៅធនាគារ***

រាល់ការផ្ញើរប្រាក់ទៅក្នុងគណនីធនាគារ ឬការដកប្រាក់ចេញពីគណនីធនាគារ ត្រូវគោរពទៅតាមគោលនយោបាយគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

រាល់ការសម្រេចលើចំណាយទាំងឡាយ ត្រូវមានការយល់ព្រមពីថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

**ប្រការ ២៤._*បេឡាសាច់ប្រាក់របស់មូលនិធិ***

*មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត អាចបើកបេឡាសាច់ របស់ខ្លួនបាន ទៅតាមការចាំបាច់ជាក់ស្តែង។*

*ថវិការបស់មូលនិធិ អាចរក្សាទុកក្នុងបេឡាសាច់ប្រាក់ នូវចំនួនសាច់ប្រាក់ មិនលើស ពី ១.០០០.០០០៛០០(មួយលានរៀល) សម្រាប់ចំណាយចាំបាច់តូចតាច។*

*រាល់ការចំណាយបេឡាសាច់ប្រាក់មូលនិធិត្រូវអនុវត្តទៅតាមគោលនយោបាយគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

**ប្រការ ២៥._*ប្រតិបត្តិការរដ្ឋបាល***

*រាល់ការចំណាយលើប្រាក់បេសកកម្ម និងថ្លៃធ្វើដំណើរសម្រាប់ក្រុមការងារ ដើម្បីយកប្រាក់ឧបត្ថមទៅប្រគល់ជូនគ្រួសារសព ឬជនរងគ្រោះ គឺត្រូវទូទាត់ចេញពីគណនីមូលនិធិមរណសង្គ្រោះ*

*រាល់ការចំណាយខាងលើ ត្រូវអនុវត្តទៅតាមគោលនយោបាយគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

**ប្រការ ២៦._*របាយការណ៍មូលនិធិ***

*រៀងរាល់ ០៣ខែម្តង អគ្គលេខាធិការសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុ របស់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ជូនថ្នាក់ដឹកនាំសមាគម និងគណៈកម្មាធិការប្រតិបត្តិសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

*រៀងរាល់ ១ឆ្នាំម្តង អគ្គលេខាធិការសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុ របស់មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ជូនក្រុមប្រឹក្សាសមាគមជាតិ។*

## ជំពូក ៩
## វិសោធនកម្ម និងការរំសាយមូលនិធិ

ប្រការ ២៧._***ការកែសម្រួល ឬវិសោធនកម្មលក្ខន្តិកៈ***

*លក្ខន្តិកៈនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្ម ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

ប្រការ ២៨._***ការរំសាយ និងការចាត់ចែងទ្រព្យសម្បត្តិ***

*ក្រុមប្រឹក្សាសមាគម នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានសិទ្ធិក្នុងការរំសាយ ឬលុបចោល មូលនិធិមរណសង្គ្រោះ។*

*ក្នុងករណីមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានរំសាយ ឬលុបចោល សម្ភារៈ ឬ/និង ថវិកា ដែលនៅសល់ត្រូវបង្វែរចូលទៅក្នុងគណនីប្រាក់សមាជិកភាពរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

## ជំពូក ១០

## អវសានប្បញ្ញត្តិ

ប្រការ ២៩._***សុពលភាពគតិយុត្ត***

*លក្ខន្តិកៈមូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។*

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០១៤*

***ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត***

**ហត្ថលេខា**